مدرسة اهل البيت

# សាលា អាស់លុល-បៃត៍

## សៀវភៅ អាក់ឡាក់ (أَخْلَاقٌ សីលធម៌)

## ថ្នាក់ទី ២ (អាយុ ៦-៧ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ الْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ អាល់-ហ្គាំឌូ លិលឡាស្ស .......... ៥
មេរៀនទី ២ យ៉ាស្មាកាល់ឡោះហ្វ៍ .......... ៧
មេរៀនទី ៣ អ៊ិនស្ហាអ្ល័ អល់ឡោះហ្វ៍ .......... ៩
មេរៀនទី ៤ សត្វលោកទាំងអស់របស់អល់ឡោះហ្វ៍មានសារៈសំខាន់ .......... ១២
មេរៀនទី ៥ សត្វលោកទាំងអស់មានសារៈសំខាន់ .......... ១៥
មេរៀនទី ៦ កុំគិតតែខ្លួនឯង .......... ១៧
មេរៀនទី ៧ ស្វូត្រស្វ៍ឡាវ៉ាត .......... ១៩
មេរៀនទី ៨ កណ្តាស់ .......... ២២
មេរៀនទី ៩ សិក្សាមេរៀន .......... ២៤
មេរៀនទី ១០ ពេលចូលដំណេក .......... ២៦
មេរៀនទី ១១ ពេលភ្ញាក់ពីដំណេក .......... ២៨

**មេរៀនទី ១**

# អាល់-ហាំឌូ លិលឡាស់
# (អរព្រះគុណអល់ឡោះហ្ ﷻ)

ថា អាល់-ហាំឌូ លិលឡាស់ (اَلْحَمْدُ لِلّٰهِ) ជារបៀបមួយសម្រាប់អរព្រះគុណអល់ឡោះហ្ ﷻ ។

អាល់-ហាំឌូ លិលឡាស់ មានន័យថា ការអរព្រះគុណទាំងអម្បាលម៉ានបានទៅអល់ឡោះហ្ ﷻ (ឬ "សូមអរព្រះគុណអល់ឡោះហ្ ﷻ") ព្រោះអល់ឡោះហ្ ﷻជាអ្នកបង្កើតសព្វសារពើ ព្រះអង្គ ﷻខ្លាំងពូកែបំផុត ។

ហេតុអ្វីគេអរព្រះគុណអល់ឡោះហ្ ﷻ ?

យើងអរព្រះគុណអល់ឡោះហ្ ﷻដែលបានប្រទានឲ្យយើងនូវអ្វីៗដែលល្អ ដូចជា៖

-ភ្នែក ។ ចូរបិទភ្នែកហើយដើរ ។ អ្នកនឹងដឹងថាពិបាកដើរពេលមើលមិនឃើញទីដៅដែលយើងដើរទៅរក ។ ចូរថា អាល់-ហាំឌូ លិលឡាស់ ដែលអ្នកមានភ្នែក ។

-ត្រចៀកសម្រាប់ស្តាប់ ។ បើអ្នកមិនមានត្រចៀកទេ អ្នកមិនឮគ្រូនិយាយក្នុងពេលនេះទេ ។ ដូច្នេះចូរថា អាល់-ហាំឌូ លិលឡាស់ ដែលអ្នកមានត្រចៀក ។

-ដៃទាំងពីរសម្រាប់ធ្វើការនានា ។ ចូរដាក់ដៃក្រោយខ្នង ហើយសាកល្បងចាប់ប៉ាកកាដោយគ្មានដៃ ។ មិនអាចធ្វើបានទេ ។ ដូច្នេះចូរថា អាល់-ហាំឌូ លិលឡាស់ ដែលអ្នកមានដៃ ។

-ជើងទាំងពីរសម្រាប់ដើរនិងលេង ។ បើគេចងជើងអ្នក តើអ្នកអាចដើរបានទេ ? ទេ ។ ដូច្នេះចូរអ្នកថា អាល់-ហាំឌូ លិលឡាស់ ដែលអ្នកមានជើង ។

-វត្ថុល្អបំផុតមួយដែលអល់ឡោះហ្ ﷻព្រះរាជទានឲ្យយើងនោះគឺខួរក្បាល ។ អាស្រ័យខួរក្បាល យើងអាចយល់អ្វីៗ អាចដឹងថាអ្វីល្អ អ្វីអាក្រក់ ។ ដូច្នេះចូរថា អាល់-ហាំឌូ លិលឡាស់ ដែលមានខួរក្បាល ។

ចូរព្យាយាមប្រើខួរក្បាលយើងដើម្បីធ្វើអំពើល្អ ដើម្បីផ្គាប់ចិត្តអល់ឡោះហ្ ﷻ

ព្រោះព្រះអង្គ عز وجل ប្រទានអ្វីៗឲ្យយើងច្រើនណាស់ ។

អល់ឡោះហ្ عز وجل ប្រទានឲ្យយើងម្ដាយនិងឪពុកដែលស្រឡាញ់យើង ដែលថែរក្សាយើង ។







ចូរគូរអ្វីៗផ្សេងទៀត ហើយអ្នកអរព្រះគុណអល់ឡោះហ្ عز وجل ដែលប្រទានអ្វីទាំងនេះឲ្យអ្នកដោយថា អាល់-ហ៊ាំឌុ លិលឡាស់ ។

## មេរៀនទី ២

# យ៉ាស្សាកាល់ឡោះហ្វ
## (អរគុណអ្នកដទៃ)

យើងជាមុស្លីម ពោលគឺ អ្វីៗដែលយើងធ្វើនោះគឺដើម្បីអល់ឡោះហ៍ﷻ ។

អល់ឡោះហ៍ﷻបានប្រាប់យើងថាមុស្លីមជាបងប្អូនគ្នា យើងត្រូវមើលថែរក្សាគ្នាទៅវិញទៅមក ។

ថា យ៉ាស្សាកាល់ឡោះហ្វ (جَزَاكَ اَللّٰهُ បើស្រីថា جَزَاكِ اَللّٰهُ) អ្នកមិនត្រឹមតែអរគុណបុគ្គលដែលអ្នកនិយាយពាក្យនេះដាក់នោះទេ តែអ្នកសម្តែងឲ្យបុគ្គលនោះឃើញដែរថាអ្នកស្រឡាញ់រាប់អានបុគ្គលនោះ អ្នកមើលថែរក្សាបុគ្គលនោះព្រោះអ្នកសូមឲ្យអល់ឡោះហ៍ﷻប្រទានរង្វាន់ឲ្យបុគ្គលនោះ ដែលបុគ្គលនោះបានធ្វើអ្វីមួយមកលើខ្លួនអ្នក ។

យ៉ាស្សាកាល់ឡោះហ្វ មានន័យថា សូមឲ្យអល់ឡោះហ៍ﷻតបស្នងអ្នក ។

ថា យ៉ាស្សាកាល់ឡោះហ្វ (ឬ យ៉ាស្សាកាគីលឡាស្ស) អ្នកមិនត្រឹមតែអរគុណបុគ្គលដែលអ្នកថាពាក្យនេះដាក់ប៉ុណ្ណោះទេ តែអ្នកសូមឲ្យអល់ឡោះហ៍ﷻប្រទានរង្វាន់យ៉ាងច្រើនឲ្យបុគ្គលនោះផងដែរដើម្បីបុគ្គលនោះនឹងបានចូលឋានសួគ៌ ។

## លំហាត់ ២

# យ៉ាសាកាល់ឡោះហ៍
# (អរគុណអ្នកដទៃ)

ចូរផាត់ពណ៌សញ្ញាប័ត្រដែលអ្នកចង់បាន ។

**សញ្ញាប័ត្រ**

ដែលបានថា

**យ៉ាសាកាល់ឡោះហ៍**

**សញ្ញាប័ត្រ**

ដែលបានថា

**អរគុណ**

**មេរៀនទី ៣**

# អ៊ិនស្ហាអ៊ុ អល់ឡោះហ៍
# (បើអល់ឡោះហ៍ចង់)

អល់ឡោះហ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះតុ៍ អាលី អ៊ីមរ៉ន អាយ៉ាស់ ៥៤ ថា៖ *"ពួកគេបានរៀបចំផែនការក្បត់ ។ អល់ឡោះហ៍ក៏រៀបផែនការដែរ ។ អល់ឡោះហ៍ប្រសប់រៀបផែនការផ្ដើម ។"*

អាយ៉ាស់នេះបញ្ជាក់ប្រាប់យើងថា ទោះបីយើងរៀបចំផែនការអ្វីក៏ដោយ បើអល់ឡោះហ៍ﷻមិនចង់ទេ ផែនការនោះនឹងមិនបានសម្រេចជាដាច់ខាត ។ ឧទាហរណ៍ ហ្វៀរអៅន៍មានគម្រោងការសម្លាប់ព្រះសាស្ដាមូសាﷺ តែអល់ឡោះហ៍ﷻបានសង្គ្រោះព្រះអង្គﷺ ។

ពេលអ្នកសម្រេចចិត្តធ្វើអ្វីមួយ អ្នកត្រូវថា៖ "ខ្ញុំនឹងធ្វើការនោះ... អ៊ិនស្ហាអ៊ុ អល់ឡោះហ៍ (إِنْ شَاءَ اللَّهُ)" ជានិច្ច ។

អ៊ិនស្ហាអ៊ុ អល់ឡោះហ៍ មានន័យថា បើអល់ឡោះហ៍ﷻចង់ អ្នកនឹងធ្វើការនោះ ។

ម្ដាយតុ៍លិបតែងតែនិយាយដដែលៗថាវាត្រូវថា អ៊ិនស្ហាអ៊ុ អល់ឡោះហ៍ ពេលវានឹងធ្វើអ្វីមួយ ។

ថ្ងៃមួយ តុ៍លិបនិយាយលេងជាមួយមិត្តវា ។ វាប្រាប់មិត្តថាវានឹងទៅលេងបុណ្យជាមួយឪពុកម្ដាយវា ។

ម្ដាយតុ៍លិបបានឮវាហើយបានបន្ទោសវា ថាវាមិនបានថាវានឹងទៅលេងបុណ្យ អ៊ិនស្ហាអ៊ុ អល់ឡោះហ៍ ។

តុ៍លិបបានតបវិញថា វាច្បាស់ជានឹងបានទៅលេងបុណ្យព្រោះឪពុកវាបានទិញសំបុត្ររួចហើយ ម្យ៉ាងទៀតគាត់បានសន្យាថានឹងនាំវាទៅលេងបុណ្យនោះ ។

យប់ទៅលេងបុណ្យ ពេលជិតចេញដំណើរ តុ៍លិបនិងឪពុកម្ដាយឡើងឡាន

ចេញដំណើរព្រោះកន្លែងបុណ្យនៅឆ្ងាយពីផ្ទះ ។

ក្រោយពីនោះបន្តិច ឡានមានសម្លេងចម្លែកហើយក៏ឈប់ង៉ក់ ។ ឪពុកត្ហ៊ុលិបចេញពីឡានទៅរកមូលហេតុ តែគាត់បញ្ឆេះឡានមិនឆេះ ។

គាត់ក៏បានទូរស័ព្ទហៅជាងជួសជុលឡាន តែទម្រាំតែជាងមកដល់ហើយជួសជុលឡានរួច ក៏ហួសពេលទៅលេងបុណ្យ ។ ត្ហ៊ុលិបនិងគ្រួសារក៏បានត្រឡប់មកផ្ទះវិញ ។

ថ្ងៃបន្ទាប់ ត្ហ៊ុលិបនិយាយសាសងជាមួយមិត្តវា គេឮវាថា អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ ពេលវាបម្រុងធ្វើអ្វីមួយ គឺៈ "ស្អែកខ្ញុំនឹងទៅសាលារៀន អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ ។ ចេញពីរៀន ខ្ញុំនឹងទៅលេងបងប្អូនជីដូនមួយ អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ ។ យើងទាំងពីរនាក់នឹងទៅដើរលេងឯផ្សារ អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ ដើម្បីទិញអំណោយថ្ងៃបុណ្យខួបកំណើតដែលនឹងប្រព្រឹត្តទៅបាន អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ យើងនឹងអាចទៅលេងបុណ្យនោះបាន អ៊ិនស្ហាអ៊្ល័ អល់ឡោះហ៊្វ័ ។"

**លំហាត់ ៣**

# អ៊ិនស្ហាអ៊្ល័ អល់ឡោះហ្ម៍
# (បើអល់ឡោះហ្ម៍ចង់)

តើតួលិបរៀនថាអ្វី ? ហេតុអ្វី ?

អ៊ិនស្ហាអ៊្ល័ អល់ឡោះហ្ម៍



ចូរផាត់ពណ៌រូបតួលិប ។

**មេរៀនទី ៤**

# សត្វលោកទាំងអស់របស់អល់ឡោះហ្ម៍ មានសារៈសំខាន់

អល់ឡោះហ្ម៍ﷻស្តាប់ការបួងសួងរបស់សត្វលោកទាំងអស់ តូចក្តី ធំក្តី ក្រក្តី មានក្តី ។ អល់ឡោះហ្ម៍ﷻស្រឡាញ់សត្វលោកទាំងអស់ ។

សម័យព្រះសាស្តាស៊ូឡៃម៉ានﷺ មានការរាំងភ្លៀងដ៏យូរ ។ ដំណាំទាំងអស់ ងាប់គ្មានសល់ មនុស្សម្នាក្របាយហូបណាស់ ។

ពួកប៉ាលេស្ទីនបានសូមព្រះសាស្តាស៊ូឡៃម៉ានﷺឲ្យបួងសួង សូមឲ្យមានភ្លៀងធ្លាក់ ។

ព្រះសាស្តាស៊ូឡៃម៉ានﷺចេញទៅបួងសួង ជាមួយប្រជារាស្ត្រព្រះអង្គﷺ ។ ព្រះអង្គﷺបានឃើញស្រមោចមួយឈរជើងពីរ លើកដៃទៅលើមេឃ ថា៖ "អល់ឡោះហ្ម៍ﷻអើយ អស់ទូលព្រះបង្គំជាខ្ញុំជាសត្វលោកតូចជាងគេបង្អស់ ។ អស់ទូលព្រះបង្គំជាខ្ញុំមិនអាចរស់រានមានជីវិត ដោយគ្មានជំនួយពីព្រះអង្គﷻបានទេ ។ អស់ទូលព្រះបង្គំជាខ្ញុំសូមព្រះអង្គﷻព្រះរាជទានភ្លៀង ឲ្យអស់ទូលព្រះបង្គំជាខ្ញុំ ដើម្បីនឹងឲ្យដើមឈើលូតលាស់ ឲ្យចម្ការមានដំណាំ ឲ្យគ្រាប់ពូជដុះដើម្បីអស់ទូលព្រះបង្គំជាខ្ញុំនឹងមានបាយអាស្រ័យ ។"

ព្រះសាស្តាﷺស៊ូឡៃម៉ានﷺដែលចេះនិយាយភាសាសត្វនោះ ក៏បានប្រាប់ឲ្យទាំងអស់គ្នាត្រឡប់ទៅកាន់លំនៅដ្ឋានវិញព្រោះការបួងសួង (ឌូអាុអ៍) របស់ស្រមោចគ្រប់គ្រាន់ហើយ ។

ភ្លៀងក៏បានធ្លាក់មកយ៉ាងច្រើន ដីក៏បានក្លាយទៅជាមានពណ៌បៃតងឡើងវិញ ។

ឧត្តមគតិរឿងនេះគឺ អល់ឡោះហ្ម៍ﷻមិនរើសអើងទេ មិនថាអ្នកជាអ្នកណាទេ

តូចក្តី ធំក្តី អល់ឡោះហ៍ﷻស្រឡាញ់អ្នកទាំងអស់គ្នា ព្រះអង្គﷻស្តាប់ការបួងសួង (ឌូអាអ៍) របស់អ្នកបើការបួងសួងនោះជាការបួងសួងស្មោះអស់ពីចិត្ត ។

# លំហាត់ ៤

តើអ្នកឃើញមានសត្វអ្វីខ្លះនៅលើរូបនេះ ?



ចូរផាត់ពណ៌រូបសត្វ ។

## មេរៀនទី ៥

# អាការរីករាយ - អាការញញឹម

ព្រះសាស្តាﷺអល់ឡោះហ្វ៍عزّ وجلّមានព្រះវចនៈថា អ្វីដែលអល់ឡោះហ្វ៍عزّ وجلّស្រឡាញ់បំផុតគឺធ្វើឲ្យអ្នកមានសទ្ធារីករាយ ។

បើអ្នករីករាយ មនុស្សនៅជុំវិញអ្នកនឹងរីករាយ ។ បើអ្នកក្រៀមក្រំ មនុស្សនៅជុំវិញអ្នកនឹងក្រៀមក្រំ ។

បើអ្នករីករាយ មនុស្សនឹងចូលចិត្តនៅក្បែរអ្នក តែបើអ្នកក្រៀមក្រំមនុស្សនឹងទុកឲ្យអ្នកនៅតែឯងព្រោះតែមិនចង់ក្រៀមក្រំដែរ ។

ពេលអ្នករីករាយ អ្នកសម្តែងឲ្យអ្នកផងឃើញថាអ្នកគាប់ចិត្តនឹងអ្វីដែលអល់ឡោះហ្វ៍عزّ وجلّប្រទានឲ្យអ្នក ។ ដូច្នេះហើយបានជាអ្នកត្រូវថា "អាល់-ហ៊ាំឌូលិលឡាស្ហ៍" ពេលអ្នកបានសម្រេចដូចបំណងនិងពេលដែលអ្នកមិនបានសម្រេចដូចបំណងទេដែរ ។

បើអ្នកក្រៀមក្រំ អ្នកសម្តែងឲ្យឃើញថាអ្នកមិនគាប់ចិត្តនឹងអ្វីៗដែលអល់ឡោះហ្វ៍عزّ وجلّបានប្រទានឲ្យអ្នកទេ ថាព្រះអង្គعزّ وجلّធ្វើមិនត្រឹមត្រូវទេ ថាអ្នកចេះជាងអល់ឡោះហ្វ៍عزّ وجلّ ។

អ៊ីម៉ាំទី ៨ របស់យើង គឺអ៊ីម៉ាំ អ្ញលី អារ-រីជ្ញ៉ំصلوات الله عليه والسلام បានថាអល់ឡោះហ្វ៍عزّ وجلّឲ្យរង្វាន់អ្នកណាដែលញញឹមពេលជួបបងប្អូនមុស្លីម ។

ទង្វើរបស់អ្នកសំខាន់ជាងសម្តីអ្នក ។ មនុស្សឃើញអ្នកមុននឹងឮអ្នក ។ ពេលអ្នកញញឹម អ្នកបង្ហាញឲ្យមនុស្សឃើញថាអ្នកស្រឡាញ់រាប់អានពួកគេ អ្នករីករាយនឹងពួកគេ ។

រាល់ពេលដែលគេខ្វះសីលធម៌ចំពោះព្រះសាស្តាﷺ ឬ ចំពោះអ៊ីម៉ាំعليهم السلام ព្រះអង្គعليهم السلامញញឹមដាក់បុគ្គលនោះ ប្រព្រឹត្តដោយមេត្រីភាពចំពោះបុគ្គលនោះ ។ បុគ្គលខ្វះសីលធម៌នោះនឹងខ្មាស់ខ្លួនឯង ។

## លំហាត់ ៥

ចូរផាត់ពណ៌ទឹកមុខដែលអល់ឡោះហ៊្ عزوجل ស្រឡាញ់ ហើយគូសខ្វែងលើទឹកមុខមួយទៀត ។



**មេរៀនទី ៦**

# កុំគិតតែខ្លួនឯង

អល់ឡោះហ្ 'ﷻ'មានព្រះបន្ទូលនៅក្នុងស៊ូរ៉ោះត៍ អាល់-ក៏ស្វស៍ អាយ៉ាស់ ៧៧ ថា៖ *"ចូរលោកប្រព្រឹត្តល្អដូចអល់ឡោះហ៍បានប្រព្រឹត្តល្អមកលើលោកដែរ ។"*

អាយ៉ាស់នេះបញ្ជាក់ប្រាប់យើងថា អ្វីៗដែលយើងមាននោះសុទ្ធតែមកពីអល់ឡោះហ៍ﷻ ។ អល់ឡោះហ៍ﷻមានព្រះបន្ទូលថា ដូចព្រះអង្គﷻបានប្រទានឲ្យយើងនោះដែរ យើងត្រូវឲ្យទៅអ្នកដទៃផងដែរ មិនត្រូវគិតតែខ្លួនឯងទេ ។

ពេលគេសូមឲ្យអ្នកធ្វើអ្វីមួយដូរនឹងអំណោយមួយ អ្នកនឹងធ្វើភ្លាម ។ ឧទាហរណ៍ បើគេសូមឲ្យអ្នកប្រញាប់ហូបបាយឲ្យអស់ពីចាន គេនឹងឲ្យរង្វាន់អ្នក អ្នកនឹងប្រញាប់ហូបបាយអស់ភ្លាម ។

អល់ឡោះហ៍ﷻប្រទានឲ្យអ្នកច្រើនណាស់ដោយមិនសូមអ្វីវិញទេ ។ ព្រះអង្គﷻបានសន្យាប្រទានឲ្យអ្នកច្រើនទៀតបើអ្នកស្តាប់ព្រះអង្គﷻ ។

សាសនាអ៊ីស្លាមបង្គាប់អ្នកឲ្យចេះមើលថែរក្សាគ្នា ។ ព្រះសាស្តាﷺមានព្រះវចនៈថាបើអ្នកណាមិនមើលថែរក្សាមុស្លីមដូចគ្នាទេ អ្នកនោះមិនមែនមុស្លីមទេ ។

គិតតែខ្លួនឯង គឺគិតតែទាញយកផលប្រយោជន៍សម្រាប់ម្នាក់ឯង ចង់បានទាំងអស់សម្រាប់តែខ្លួនឯងមួយ មិនគិតដល់អ្នកដទៃទេ ។

មនុស្សដែលគិតតែខ្លួនឯងមិនមានមិត្តទេ ព្រោះមនុស្សនោះមិនបែងចែកឲ្យអ្នកដទៃទេ ចង់បានទាំងអស់តែម្នាក់ឯង ។

អល់ឡោះហ៍ﷻមិនចូលចិត្តឲ្យអ្នកគិតតែខ្លួនឯងទេ ។ អល់ឡោះហ៍ﷻមានព្រះបន្ទូលថាបើអ្នកឲ្យអ្នកដទៃមួយ ព្រះអង្គﷻនឹងឲ្យអ្នកវិញមួយរយព្រោះព្រះអង្គﷻចិត្តល្អលើសគេ ។

## លំហាត់ ៦

# កុំគិតតែខ្លួនឯង

ចូរគូសខ្វែងលើរូបមនុស្ស ដែលអ្នកឃើញថាជាមនុស្សដែលគិតតែខ្លួនឯង ព្រោះអ្នកមិនចង់ដូចមនុស្សនោះទេ ។



**មេរៀនទី ៧**

# សូត្រស្វ៉ឡាវ៉ាត

អល់ឡោះហ្ជ៍ عزوجلមានព្រះបន្ទូលនៅក្នុងព្រះមហាគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាស់ស្ហាប់ អាយ៉ាស់ ៥៦ ថា៖ *"អល់ឡោះហ្ជ៍និងបណ្ដាទេវតារបស់ព្រះអង្គជូនពរជ័យសិរីសួស្ដីដល់ព្រះសាស្ដា ។ បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកជូនពរជ័យសិរីសួស្ដីដល់គេ..."*

ស្វ៉ឡាវ៉ាតគឺសូត្រថា៖ اَللَّهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِ مُحَمَّدٍ មានន័យថា៖ អល់ឡោះហ្ជ៍ عزوجلអើយ សូមព្រះអង្គ عزوجلព្រះរាជទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់ صلى الله عليه وآله وسلم និងដល់អាស់លុល-បៃត៍ عليهم السلام ។

អាស់លុល-បៃត៍ មានន័យថា "ព្រះរាជកុលដ្ឋាន" ពោលគឺអ្នកផ្ទះ ។ អ្នកផ្ទះគឺគ្រួសាររបស់ព្រះសាស្ដាមូហាំម៉ាដ់ صلى الله عليه وآله وسلم គឺ ប៊ីប៊ី ហ្វាទិម៉ាស់ سلام الله عليها និងអ៊ីម៉ាំទាំង ១២ អង្គ عليهم السلام ។ រាល់ពេលដែលអ្នកឮព្រះនាមព្រះសាស្ដា صلى الله عليه وآله وسلم និងសមាជិកណាមួយនៃព្រះរាជកុលដ្ឋាន عليهم السلام (ពោលគឺ គ្រួសារព្រះអង្គ صلى الله عليه وآله وسلم គឺ អាស់លុល-បៃត៍ عليهم السلام) អ្នកត្រូវសូត្រស្វ៉ឡាវ៉ាត ។

ពេលអ្នកឮព្រះនាមរបស់អ៊ីម៉ាំទី ១២ របស់យើង គឺ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី صلوات الله عليه والسلام អ្នកមិនត្រឹមតែសូត្រស្វ៉ឡាតវ៉ាតប៉ុណ្ណោះទេ តែអ្នកត្រូវងើបឡើងផង ដោយដាក់ដៃលើថ្ងាសហើយឱនក្បាល ។ ធ្វើដូច្នេះពីព្រោះអ៊ីម៉ាំទី ១២ របស់យើង صلوات الله عليه والسلام នៅរស់នៅឡើយ ។

ពេលអ្នកអង្គុយស្ងៀមឥតការធ្វើ (នៅឯម៉ាស់យ៉ិដ្ឋ មិនយល់គេនិយាយគ្នាអ្វីទេនោះ) អ្នកត្រូវសូត្រស្វ៉ឡាវ៉ាតឲ្យច្រើនតាមដែលអាចធ្វើបាន ។

ពេលអ្នកសូត្រស្វ៉ឡាវ៉ាត អ្នកសូមឲ្យអល់ឡោះហ្ជ៍ عزوجلប្រទានពរជ័យឲ្យទៅព្រះសាស្ដា صلى الله عليه وآله وسلم និងអាស់លុល-បៃត៍ عليهم السلام ព្រះអង្គ صلى الله عليه وآله وسلم ។ អ៊ិនស្ហាអ៊ ់ អល់ឡោះហ្ជ៍ ថ្ងៃ

គឺយ៉ាម៉ាត់ព្រះសាស្តា ﷺ និងអាស់លុល-បៃត៍ عليهم السلام ព្រះអង្គ ﷺ នឹងសូមឲ្យអល់ឡោះហ៊ូ عز وجل លើកលែងទោសឲ្យអ្នក ជារង្វាន់តបស្នងស្វ៊ឡាវ៉ាតទាំងអស់ដែលអ្នកបានសូត្រឲ្យទៅព្រះអង្គទាំងអស់ عليهم السلام ។

**លំហាត់ ៧**

## ស្វ៉ូឡាវ៉ាត اَللّٰهُمَّ صَلِّ عَلَى مُحَمَّدٍ وَ آلِ مُحَمَّدٍ

ចូរគូរចំនួនគ្រាប់តាស់ប៊ិះហ៍ានៅលើតាស់ប៊ិះហ៍អ្នក ដែលអ្នកត្រូវការដើម្បីសូត្រស្វ៉ូឡាវ៉ាតឲ្យទៅព្រះសាស្តាﷺនិងអាស្ល់លុល-បៃត៍عليهم السلامព្រះអង្គﷺ ។



## មេរៀនទី ៨

# កណ្តាស់

ពេលអ្នកកណ្តាស់ អ្នកត្រូវថា៖ اَلْحَمْدُ لِلَّٰهِ អាល់-ហ្ាំឌូ លិលឡាស៊ូ មានន័យថា សេចក្តីកោតសរសើរទាំងអម្បាលម៉ានបានទៅអល់ឡោះហ៊ូ ﷻ (ឬ សូមថ្វាយសេចក្តីកោតសរសើរចំពោះអល់ឡោះហ៊ូ ﷻ ។

គេថាពេលយើងដើបពីក្នុងផ្នូរយើងថ្ងៃគ្ហីយ៉ាម៉ាត្ហ៍ យើងនឹងដើបឡើងវិញដោយកណ្តាស់ ។

បើអ្នកមានទម្លាប់ថា "អាល់-ហ្ាំឌូ លិលឡាស៊ូ" រាល់ពេលដែលអ្នកកណ្តាស់ ថ្ងៃគ្ហីយ៉ាម៉ាត្ហ៍អ្នកនឹងថា "អាល់-ហ្ាំឌូ លិលឡាស៊ូ" ដែរពេលអ្នកភ្ញាក់ខ្លួនឡើងក្រោយពីកណ្តាស់រួច ។

ពេលអ្នកកណ្តាស់អ្នកត្រូវយកដៃបាំងមាត់ផង ដើម្បីនឹងកុំឲ្យមេរោគ (មីក្រុប) ខ្ចាយទៅលើអ្នកដទៃ នឹងបណ្តាលឲ្យឆ្លងជម្ងឺ ។

ពេលអ្នកដទៃកណ្តាស់ អ្នកត្រូវថា៖ يَرْحَمُكَ اللَّهُ យ៉ារហ្ាមូកាល់-ឡាស៊ូ បើអ្នកកណ្តាស់ជាស្រី អ្នកត្រូវថា يَرْحَمُكِ اللَّهُ យ៉ារហ្ាមូគីល-ឡាស៊ូ មានន័យថា៖ "សូមអល់ឡោះហ៊ូឲ្យពរអ្នក" ។

ដែលអ្នកថា "យ៉ារហ្ាមូកាល់-ឡាស៊ូ/យ៉ារហ្ាមូគីល-ឡាស៊ូ" ពេលអ្នកដទៃកណ្តាស់នោះ ព្រោះតែអ៊ីស្លាមបង្ហាត់បង្រៀនអ្នកឲ្យចេះមើលថែរក្សាអ្នកដទៃ ។ (រាយការណ៍តមកពី អ៊ីម៉ាំទី ១២ صلوات الله عليه والسلام)

**លំហាត់ ៨**

# កណ្ដាស់

ព្រមនឹងពេលអ្នកផាត់ពណ៌រូបនេះ ចូរនឹកស្មានថាអ្នកកណ្ដាស់ហើយថា៖

اَلْحَمْدُ لِلّٰهِ

*សូមថ្វាយសេចក្ដីកោតសរសើរទាំងអម្បាលម៉ានចំពោះអល់ឡោះហ្ទ័ ។*



**មេរៀនទី ៩**

# សិក្សាមេរៀន

អ្នកត្រូវចាប់ផ្ដើមធ្វើអ្វីៗដោយសូត្របួងសួងអល់ឡោះហ្ ជាសះថា៖

بِسْمِ اَللهِ اَلرَّحْمٰنِ اَلرَّحِيْمِ

*ដោយនូវព្រះនាមអល់ឡោះហ្ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

រួចហើយ មុនមើលមេរៀន ចូរអ្នកថា៖ رَبِّيْ زِدْنِ عِلْمًا មានន័យថា៖ "ព្រះម្ចាស់ ទូលព្រះបង្គំជាខ្ញុំអើយ សូមព្រះអង្គ បង្កើនចំណេះទូលព្រះបង្គំជាខ្ញុំ ។"

ចំណេះគឺអ្វីដែលអ្នករៀននិងដឹង ។ រៀននិងដឹងអ្វីៗមិនមែនជាសារៈសំខាន់តែម្យ៉ាងទេ តែត្រូវអនុវត្តិដោយយល់ចំណេះនោះផង ពុំនោះទេចំណេះនោះនឹងឥតប្រយោជន៍ ។

មុស្លីមគ្រប់រូបមានករណីយកិច្ចស្វែងរកចំណេះនិងសិក្សាឲ្យបានច្រើន តាមដែលអាចធ្វើបាន ។ ដើម្បីទទួលយកចំណេះអ្នកត្រូវស្ដាប់គេបង្ហាត់បង្រៀនអ្នក កុំនិយាយ ។

អ្នកត្រូវអរគុណអ្នកដែលបង្ហាត់បង្រៀនអ្នក ។ អ្នកត្រូវប្រើចំណេះនេះដើម្បីនឹងឲ្យខ្លួនឯងទៅជាមនុស្សល្អប្រសើរជាងមុន អ្នកត្រូវយកចំណេះនេះទៅបង្ហាត់បង្រៀនអ្នកដទៃវិញដែរ (គឺបង្ហាត់ប្អូនប្រុសស្រីរបស់អ្នកនិងមិត្តអ្នក) ។

ពេលអ្នកធ្វើលំហាត់ អ្នកត្រូវផ្ដោតអារម្មណ៍ទៅលើអ្វីដែលអ្នកកំពុងធ្វើ ។

**លំហាត់ ៩**

# សិក្សាមេរៀន

ចូរអ្នកចងចាំក្នុងចិត្តថាអ្នកត្រូវថាៈ




ចូរអ្នកចងចាំថាអ្នកត្រូវផ្ដោតអារម្មណ៍ទៅលើមេរៀន មិនមើលទូរទស្សន៍ផងទេ ។

**មេរៀនទី ១០**

# ពេលចូលដំណេក

មុនចូលដំណេកអ្នកត្រូវដុសធ្មេញនិងយកទឹកវូឌុអ៍ ។

អ្នកត្រូវឱបឪពុកម្ដាយហើយថា ហ្វី អាម៉ានីលឡាស់ (فِي أَمَانِ اللَّه) ឬ ឃូដា ហាហ្វ៊ីស្ទ (خُدَا حَافِظ) ។

មុននឹងដេកអ្នកត្រូវគិតដល់អ្វីៗដែលបានកើតឡើងកាលពីថ្ងៃ ។

ចូរអ្នកគិតដល់ទង្វើល្អនិងទង្វើអាក្រក់ដែលអ្នកបានធ្វើកាលពីថ្ងៃ ។ ចូរអ្នកគិតដល់ទេវតាទាំងពីរ តើទេវតាមួយណាដែលបានកត់ត្រាច្រើនជាងគេក្នុងថ្ងៃនេះ ។ ទេវតាលើស្មាស្ដាំអ្នកកត់ទង្វើល្អទាំងអស់របស់អ្នក ឬទេវតាលើស្មាឆ្វេងអ្នកកត់ទង្វើអាក្រក់ទាំងអស់របស់អ្នក ?

ចូរសូមទោសអល់ឡោះហ៊្វ‍ﷻដែលអ្នកបានធ្វើអំពើអាក្រក់ ហើយចូរសន្យាថាអ្នកលែងធ្វើទៀត ។ បើអ្នកបានកាច (គឺប្រព្រឹត្តមិនគប្បី) ដាក់អ្នកណាម្នាក់ ចូរអ្នកប្រាប់ខ្លួនឯងថានឹងទៅសូមទោសអ្នកនោះថ្ងៃស្អែក ។

អ្នកត្រូវដេកលើខ្នង (គឺផ្ងារពោះ) ឬ លើចំហៀងខ្លួនខាងស្ដាំ ។ ចំណែកឯស្ទៃតួនﷺវិញ វាដេកផ្កាប់មុខ ។

ទីបំផុត មុនបិទភ្នែក ចូរគិតដល់អល់ឡោះហ៊្វ‍ﷻដោយសូត្រស៊ូរ៉ោះតូចៗមួយដើមដែលអ្នកចេះ ហើយចូរអរព្រះគុណអល់ឡោះហ៊្វ‍ﷻអំពីអ្វីៗទាំងអស់ ។

បន្ទាប់ពីនោះចូរសូត្រថា៖ اللَّهُمَّ بِاسْمِكَ أَحْيَى وَ أَمُوْتُ មានន័យថា៖ អល់ឡោះហ៊្វ‍ﷻអឺយ ទូលព្រះបង្គំជាខ្ញុំរស់និងស្លាប់ក្នុងព្រះនាមព្រះអង្គﷻ (ព្រោះដេកលក់ជាការស្លាប់ តែបណ្ដោះអាសន្ន គឺស្លាប់មួយពេលតូច) ។

## លំហាត់ ១០

# ពេលចូលដំណេក

ចូរកុំភ្លេចដុសធ្មេញនិងយកទឹកវូឌុអ៍ ។





ចូរទន្ទេញឲ្យចាំ ៖

اللَّهُمَّ بِاسْمِكَ أَحْيَ وَ أَمُوْتُ



## មេរៀនទី ១១

# ពេលភ្ញាក់ពីដំណេក

រាល់ព្រឹក ពេលអ្នកភ្ញាក់ពីដេក ចូរអ្នកចាប់ផ្តើមថ្ងៃថ្មីដោយសូត្រឌូអាអ៊ុំនេះគឺ៖

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ

اَلْحَمْدُ لِلّٰهِ الَّذِيْ أَحْيَانَا بَعْدَ مَا أَمَاتَنَا وَ إِلَيْهِ النُّشُوْرُ

*ដោយនូវព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។*

*សូមថ្វាយសេចក្តីកោតសរសើរចំពោះអល់ឡោះហ្ម៍ ﷻ ដែលប្រទានជីវិតឲ្យអស់ទូលព្រះបង្គំជាខ្ញុំក្រោយពីការស្លាប់ ។ អស់ទូលព្រះបង្គំជាខ្ញុំនឹងវិលត្រឡប់ទៅឯព្រះអង្គ ﷻ វិញ ។*

ដេកប្រៀបបាននឹងការស្លាប់ គឺយើងចាកចេញទៅឯអល់ឡោះហ្ម៍ ﷻ តែអល់ឡោះហ្ម៍ ﷻ ឲ្យយើងត្រឡប់មកវិញ ។ ពេលយើងស្លាប់ យើងនឹទៅឯអល់ឡោះហ្ម៍ ﷻ ហើយយើងនឹងនៅជាមួយអល់ឡោះហ្ម៍ ﷻ ។ យើងនឹងមិនអាចត្រឡប់មកវិញបានទេ ។

នៅក្នុងឌូអាអ៊ុំខាងលើនេះ អ្នកអរព្រះគុណអល់ឡោះហ្ម៍ ﷻ ដែលឲ្យអ្នកអាចត្រឡប់មកកាន់ផែនដីវិញ ហើយអ្នកទូលអល់ឡោះហ្ម៍ ﷻ ផងដែរថាអ្នកដឹងថានឹងបានវិលត្រឡប់មកជួបព្រះអង្គ ﷻ វិញ ។

ពេលអ្នកសូត្រឌូអាអ៊ុំរួច ចូរអ្នកងើបពីគ្រែហើយទៅគោះទ្វារបន្ទប់ឪពុកម្តាយអ្នក ។

ពេលឪពុកម្តាយអ្នកបានអនុញ្ញាតឲ្យអ្នកចូលជួបហើយ ចូរអ្នកចូលទៅក្នុងបន្ទប់ ទៅឱបឪពុកម្តាយដោយថា៖

اَلسَّلَامُ عَلَيْكُمْ

បន្ទាប់ពីនោះអ្នកត្រូវពាក់ស្បែកជើងហើយទៅបង្គន់ ។

លំហាត់ ១១

# ពេលភ្ញាក់ពីដំណេក



ចូរអ្នកទន្ទេញ៖

بِسْمِ اَللهِ اَلرَّحْمٰنِ اَلرَّحِيْمِ

اَلْحَمْدُ لِلّٰهِ الَّذِيْ أَحْيَانَا بَعْدَ مَا أَمَاتَنَا وَ إِلَيْهِ النُّشُوْرُ

